## ៥ ព័ត៌មានបន្ថែម

លោកអ្នកអាចសាកសួរអ្នកកាន់អាជ្ញាបណ្ណ (អ្នកផ្គត់ផ្គង់អគ្គិសនី) នៅក្នុងតំបន់លោកអ្នករស់នៅ ឬទំនាក់ទំនងមកមន្ត្រីនាយកដ្ឋានមូលនិធិអគ្គិសនីភាវូបនីយកម្មជនបទនៃអគ្គិសនីកម្ពុជា តាមទូរស័ព្ទសេវាកម្មបន្ទាន់លេខ 015776-770 / 089 776-770 ។




**អាសយដ្ឋាន៖**

អគារលេខ២០៥ ផ្លូវជាតិលេខ៥ សង្កាត់គីឡូម៉ែត្រលេខ៦ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ។

ទូរស័ព្ទៈ (៨៥៥) ៩៩៧ ៦០០ ទូរសារៈ (៨៥៥) ៩៩៧ ៦០១។

គេហទំព័រៈ www.ref.gov.kh

**អគ្គិសនីកម្ពុជា**



# ថាមពលសម្រាប់គ្រប់ៗគ្នា
# កម្មវិធីលើកកម្ពស់ការតភ្ជាប់ចរន្តអគ្គិសនីពីប្រព័ន្ធបណ្តាញជាតិ សម្រាប់គ្រួសារក្រីក្រមានប័ណ្ណសមធម៌ (ប័ណ្ណក្រីក្រ) នៅតំបន់ជនបទ ក្នុងព្រះរាជាណាចក្រកម្ពុជា

## ១ សេចក្ដីផ្ដើម

អគ្គិសនីកម្ពុជាបានទទួលថវិកាពីធនាគារអភិវឌ្ឍន៍អាស៊ី សម្រាប់លើកកម្ពស់ប្រជាពលរដ្ឋក្រីក្រនៅតំបន់ជនបទឲ្យទទួលបានអគ្គិសនីប្រើប្រាស់គ្រប់ៗគ្នា។ គោលបំណងនៃកម្មវិធី គឺបង្កើនការតភ្ជាប់ចរន្តអគ្គិសនីពីប្រព័ន្ធបណ្ដាញជាតិ ដោយជួយដល់គ្រួសារក្រីក្រមានប័ណ្ណសមធម៌ (ប័ណ្ណក្រីក្រ) សម្រាប់ការចំណាយលើការតភ្ជាប់ចរន្តអគ្គិសនីដំបូង។ កម្មវិធីនេះអនុវត្តន៍ ដោយនាយកដ្ឋានមូលនិធិអគ្គិសនីភាវូបនីយកម្មជនបទនៃអគ្គិសនីកម្ពុជា បន្ទាប់ពីនេះហៅថា "ម.អ.ជ."។

កម្មវិធីនេះរៀបចំឡើងដើម្បីជួយដល់គ្រួសារក្រីក្រមានប័ណ្ណសមធម៌សម្រាប់ ១- ចំណាយលើសម្ភារៈ និងពាយខ្សែបណ្ដាញសេវាកម្មពីចំណុចភ្ជាប់ចរន្ត (នាឡិកាស្ទង់លើបង្គោល) មកដល់ផ្ទះ និង២-ចំណាយលើការរៀបចំខ្សែបណ្ដាញ និងសម្ភារៈអគ្គិសនីក្នុងផ្ទះ ដើម្បីតភ្ជាប់ចរន្តអគ្គិសនីពីខ្សែបណ្ដាញជាតិចូលផ្ទះក្នុងតំបន់អ្នកកាន់អាជ្ញាបណ្ណដែលបានទទួលការយល់ព្រមពីគម្រោង។

កម្មវិធីនេះ គឺផ្ដល់ប្រាក់ឧបត្ថម្ភធនដល់គ្រួសារក្រីក្រមានប័ណ្ណសមធម៌ (អ្នកទទួលផល) ដោយប្រាក់ឧបត្ថម្ភធននេះនឹងទូទាត់ដោយផ្ទាល់ឲ្យទៅអ្នកកាន់អាជ្ញាបណ្ណ បន្ទាប់ពីអ្នកកាន់អាជ្ញាបណ្ណបានតភ្ជាប់ចរន្តដល់អ្នកទទួលផល និងបានពិនិត្យដោយភ្នាក់ងារផ្ទៀងផ្ទាត់ឯករាជ្យ។



គ្រួសារក្រីក្រជាច្រើនមិនចង់ភ្ជាប់ចរន្តពីប្រព័ន្ធបណ្ដាញជាតិ ដោយសារថ្លៃភ្ជាប់ចរន្តដំបូងខ្ពស់ ជាហេតុធ្វើឲ្យគ្រួសារទាំងនេះពុំអាចទទួលបានចរន្តអគ្គិសនីប្រើប្រាស់ពីប្រព័ន្ធបណ្ដាញជាតិដែលមានគុណភាព អាចរកប្រាក់ចំណូលពីការធ្វើអាជីវកម្ម និងបង្កើនសុខុមាលភាព។ ផ្ទុយទៅវិញគ្រួសារក្រីក្រទាំងនេះ បែរជាបានចំណាយច្រើនលើការប្រើប្រាស់ចរន្តអគ្គិសនីដែលមានគុណភាពអន់ និងមានតម្លៃថ្លៃ ដូចជាការប្រើប្រាស់អាគុយរថយន្តជាដើម។

## ២ តើនរណាអាចដាក់ពាក្យស្នើសុំ

កម្មវិធីនេះបានបង្កើតឡើងដើម្បីជួយដល់គ្រួសារជនបទដែលមានលក្ខណៈវិនិច្ឆ័យ ដូចខាងក្រោម៖



- គ្រួសារក្រីក្រមានប័ណ្ណសមធម៌មានសុពលភាព និងមានលំនៅដ្ឋានចម្ងាយខ្សែបណ្ដាញសេវាកម្ម (ពីចំណុចភ្ជាប់ចរន្ត/នាឡិកាស្ទង់លើបង្គោល) មកដល់ផ្ទះ ហួតដល់ ១៥០ម៉ែត្រ។
- រស់នៅក្នុងតំបន់មានការផ្គត់ផ្គង់អគ្គិសនីពីប្រព័ន្ធបណ្ដាញជាតិ។
- រស់នៅក្នុងខេត្តបន្ទាយមានជ័យ សៀមរាប កំពង់ចាម ត្បូងឃ្មុំ កំពង់ធំ និងកណ្ដាល។
- ពុំទាន់មានចរន្តអគ្គិសនីប្រើប្រាស់ពីប្រព័ន្ធបណ្ដាញជាតិ។
- មានបំណង និងមានលទ្ធភាពបង់ថ្លៃតភ្ជាប់ចរន្ត និងប្រាក់កក់ធានាថ្លៃប្រើប្រាស់អគ្គិសនីសរុបចំនួន 61,000រៀល (សម្រាប់ការតភ្ជាប់ចរន្តកម្លាំង ៥អំពែរ) ឬចំនួន 122,000រៀល (សម្រាប់ការតភ្ជាប់ចរន្តកម្លាំង ១០អំពែរ)។

## ៣ ដំណាក់កាលនៃដាក់ពាក្យស្នើសុំ

ប្រសិនបើគ្រួសារលោកអ្នកលក្ខណៈគ្រប់គ្រាន់តាមលក្ខណៈវិនិច្ឆ័យ (ដូចក្នុងចំណុចទី២- តើនរណាអាចដាក់ពាក្យស្នើសុំ) និងមានបំណងភ្ជាប់ចរន្តតាមរយៈកម្មវិធីនេះ ដំណាក់កាលបន្ទាប់មានដូចខាងក្រោម៖



- លោកអ្នកអាចសាកសួរអ្នកកាន់អាជ្ញាបណ្ណក្នុងតំបន់លោកអ្នករស់នៅ និងពិភាក្សាពីលក្ខខណ្ឌនានា។
- បន្ទាប់មក អ្នកកាន់អាជ្ញាបណ្ណត្រូវធ្វើការគណនាចំនួនសម្ភារៈអគ្គិសនីចាំបាច់នានាសម្រាប់ការតភ្ជាប់ចរន្ត។
- ប្រសិនបើឯកភាពគ្នា លោកអ្នកត្រូវចុះកិច្ចសន្យាជាមួយអ្នកកាន់អាជ្ញាបណ្ណ និងរង់ចាំការសម្រេច។
- បន្ទាប់មកទៀត អ្នកកាន់អាជ្ញាបណ្ណត្រូវដាក់លិខិតស្នើសុំការពិនិត្យសម្រេចពី ម.អ.ជ.។
- ប្រសិនបើ ម.អ.ជ. យល់ព្រមលើការស្នើសុំតភ្ជាប់ចរន្តនេះ លោកអ្នកត្រូវបង់ថ្លៃភ្ជាប់ចរន្ត និងប្រាក់កក់ធានាថ្លៃប្រើប្រាស់អគ្គិសនីឲ្យទៅអ្នកកាន់អាជ្ញាបណ្ណ ចំនួន 61,000រៀល សម្រាប់ការតភ្ជាប់ចរន្តកម្លាំង ៥អំពែរ និងចំនួន 122,000រៀល សម្រាប់ការតភ្ជាប់ចរន្តកម្លាំង ១០អំពែរ។



- បន្ទាប់ពីបានបង់ថ្លៃភ្ជាប់ចរន្ត និងប្រាក់កក់ធានាថ្លៃប្រើប្រាស់អគ្គិសនី អ្នកកាន់អាជ្ញាបណ្ណត្រូវរៀបចំខ្សែបណ្ដាញ និងសម្ភារៈអគ្គិសនីក្នុងផ្ទះ រួមមានឌីស្យុងទ័រចំនួន១គ្រាប់ អំពូលបំភ្លឺ LED ចំនួន២គ្រាប់ កុងតាក់ចំនួន២គ្រាប់ ព្រីភ្លើងមានរន្ធដោតពីរចំនួន១គ្រាប់ និងខ្សែចម្លងពីចំណុចភ្ជាប់ចរន្ត (នាឡិកាស្ទង់លើបង្គោល) មកដល់ផ្ទះ។
- អ្នកកាន់អាជ្ញាបណ្ណត្រូវផ្ដល់ខិត្តប័ណ្ណសុវត្ថិភាពស្ដីពីការបង្ការគ្រោះថ្នាក់ដែលអាចបណ្ដាលមកពីចរន្តអគ្គិសនីដល់លោកអ្នក និងកូនចៅលោកអ្នក។

## ៤ ចំនួនកំណត់នៃអ្នកទទួលផល



កម្មវិធីនេះអាចជួយដល់គ្រួសារក្រីក្រមានប័ណ្ណសមធម៌ចំនួនតែ 10,000 គ្រួសារ ដែលបានបំពេញលក្ខខណ្ឌមុនគេប៉ុណ្ណោះ សម្រាប់ការតភ្ជាប់ចរន្តក្រោមកម្មវិធីនេះ។



កុំធ្វើការងារអគ្គិសនីពេលភ្លៀង
ព្យុះ រន្ទះ




ប្រយ័ត្ន: ចរន្តអគ្គិសនីអាចមាន
ក្នុងខ្សែចម្លងគ្រប់ពេល

**ព័ត៌មានបន្ថែម៖**

លោកអ្នកអាចសាកសួរអ្នកផ្គត់ផ្គង់អគ្គិសនីនៅក្នុងតំបន់លោកអ្នករស់នៅ ឬ ទំនាក់ទំនងមកមន្ត្រីនាយកដ្ឋានមូលនិធិអគ្គិសនីភាវូបនីយកម្មជនបទ នៃអគ្គិសនីកម្ពុជា តាមទូរស័ព្ទសេវាកម្មបន្ទាន់លេខ 015 776-770 / 089 776-770 ។

អាសយដ្ឋាន: អាគារលេខ ២០៤ ផ្លូវជាតិលេខ ៥ សង្កាត់គីឡូម៉ែត្រលេខ ៦
ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ
ទូរស័ព្ទ : (855) 997 600
ទូរសារ : (855) 997 601
គេហទំព័រ : www.ref.gov.kh

## អគ្គិសនីកម្ពុជា

# ចរន្តអគ្គិសនីអាចបង្កឲ្យមានគ្រោះថ្នាក់ ត្រូវប្រុងប្រយ័ត្នជានិច្ច



**ចាមពលសម្រាប់គ្រប់ៗគ្នា**

កម្មវិធីលើកកម្ពស់ការតភ្ជាប់ចរន្តអគ្គិសនីពីប្រព័ន្ធបណ្តាញជាតិ
សម្រាប់គ្រួសារក្រីក្រមានប័ណ្ណសមធម៌ (ប័ណ្ណក្រីក្រ) នៅតំបន់ជនបទ
ក្នុងព្រះរាជាណាចក្រកម្ពុជា

ប្រសិនបើឃើញមានខ្សែបណ្ដាញអគ្គិសនីធ្លាក់ ឬ ដាច់ ឬ
គ្រប់បញ្ហាមិនប្រក្រតីនៃសម្ភារៈអគ្គិសនី
ត្រូវផ្ដល់ព័ត៌មានឲ្យអ្នកទទួលខុសត្រូវ





ការឆក់អគ្គិសនីអាចគ្រោះថ្នាក់ដល់ជីវិត





កុំយកលោហៈធាតុ ឬ ទឹកទៅប៉ះ ឬកាត់សម្ភារៈអគ្គិសនី
ព្រោះអាចបណ្ដាលឲ្យមានគ្រោះថ្នាក់ដល់ជីវិត





ចរន្តអគ្គិសនីឆក់តាមជើងទទេលើដីសើម



ចរន្តអគ្គិសនីឆក់តាមទឹកនោម

អគ្គិសនីអាចបង្កគ្រោះអគ្គីភ័យ





ការងារតភ្លើងជាកិច្ចការរបស់
អ្នកមានបទពិសោធន៍បច្ចេកទេស



ត្រូវថែទាំសម្ភារៈអគ្គិសនីឲ្យបានល្អ



